# តារាងមាតិកាសម្រាប់កញ្ចប់សៀវភៅណែនាំ

ឯកសារដែលមាននៅក្នុង កញ្ចប់សៀវភៅណែនាំនេះ រួមមានដូចជា កញ្ចប់អ្នកសម្របសម្រួល គំនិតបន្ថែមសម្រាប់កញ្ចប់អ្នកសម្របសម្រួល ឯកសារបន្ថែមសម្រាប់កិច្ចប្រជុំ និងតារាងឯកសារបទបង្ហាញ សម្រាប់អ្នកសម្របសម្រួល។

**កញ្ចប់អ្នកសម្របសម្រួល៖ ធនធានសម្រាប់សម្របសម្រួលក្នុងកិច្ចប្រជុំនៃក្រុមតូចមួយ។**

**ទំព័រ 3-4៖** ព័ត៌មានអំពីដំណើរការរៀបចំគម្រោង Kensington
**ទំព័រ 5៖** ប្រវត្តិនៃគោលដៅដែលបានកំណត់របស់សហគមន៍
**ទំព័រ 6៖** តារាងត្រួតពិនិត្យសម្រាប់កញ្ចប់កិច្ចប្រជុំ
**ទំព័រ 7៖** កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ
**ទំព័រ 8៖** ការណែនាំអំពី វិធីដែលអាចទទួលបានអត្ថប្រយោជន៍កាន់តែច្រើន ពីសៀវភៅណែនាំនេះ
**ទំព័រ 9៖** ការណែនាំអំពី ចំណុចដែលមាននៅក្នុងកញ្ចប់អ្នកសម្របសម្រួល ដែលរួមមានទាំងខិត្តប័ណ្ណមួយសម្រាប់ផ្សព្វផ្សាយ អំពីកិច្ចប្រជុំរបស់អ្នក!
**ទំព័រ 10៖** ខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយកិច្ចប្រជុំរបស់អ្នក។
**ទំព័រ 11-12៖** របៀបវារៈនៃកិច្ចប្រជុំជាក្រុម។
**ទំព័រ 13-17៖** កំណត់សម្គាល់និងការណែនាំសម្រាប់អ្នកសម្របសម្រួល សម្រាប់ការធ្វើបទបង្ហាញ PowerPoint ដល់ក្រុម (សូមមើលឧបសម្ព័ន្ធ សម្រាប់ការធ្វើបទបង្ហាញពេញលេញ)
**ទំព័រ 18៖** រង្វាស់ដើម្បីកំណត់ភាពបន្ទាន់នៃកិច្ចការអាទិភាពដែលបានពិភាក្សានៅអំឡុងកិច្ចប្រជុំរបស់អ្នក។
**ទំព័រ 19៖** កិច្ចព្រមព្រៀងនៃកិច្ចប្រជុំសម្រាប់ការប្រើប្រាស់ដើម្បីទទួលបានការសន្ទនាដែលអំណោយផលល្អមួយ
**ទំព័រ 20-21៖** តារាងកត់ត្រាការចូលរួម។ យើងខ្ញុំចង់ដឹងថាអ្នកណាខ្លះបានចូលរួមកិច្ចប្រជុំរបស់អ្នក!
**ទំព័រ 22៖** វិធីទាក់ទង NKCDC ឬសេវាកម្ម Impact Services - យើងខ្ញុំត្រៀមខ្លួនក្នុងការផ្តល់ព័ត៌មានបន្ថែម ហើយក៏ដើម្បីជួយគាំទ្រដល់អ្នក និងក្រុមរបស់អ្នកនៅក្នុងការសម្របសម្រួលដល់កិច្ចប្រជុំ។

## គំនិតបន្ថែមសម្រាប់កញ្ចប់អ្នកសម្របសម្រួល៖ ធនធានសម្រាប់សម្របសម្រួលក្នុងកិច្ចប្រជុំក្រុមតូច។

**ទំព័រ 24៖** ការចូលរួមក្នុងសហគមន៍ 101
**ទំព័រ 25៖** រូបភាពនៃ ការមកកាន់តុ
**ទំព័រ 26៖** វិធីតាមដានបន្តបន្ទាប់ ដើម្បីរក្សាបរិយាកាសល្អសម្រាប់កិច្ចប្រជុំ
**ទំព័រ 27៖** សំណួរសម្រាប់សាកសួរខ្លួនអ្នក ក្នុងនាមជាអ្នកសម្របសម្រួល
**ទំព័រ 28៖** ការព្រាងសំណួរ
**ទំព័រ 29៖** ពាក្យ និងនិយមន័យដែលបានប្រើប្រាស់ជាញឹកញាប់
**ទំព័រ 30៖** រូបភាពនៃ ការយល់ដឹងអំពីទង្គិចសតិអារម្មណ៍
**ទំព័រ 31៖** កត្តាសង្គមដែលជះឥទ្ធិពលលើសុខភាព

**ឯកសារបន្ថែមសម្រាប់កិច្ចប្រជុំ៖ សម្ភារសម្រាប់ផ្តល់ជូន និងសម្រាប់ក្រុមរបស់អ្នកធ្វើការបំពេញ។**

**ទំព័រ 33៖** កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ ជាភាសាអង់គ្លេស
**ទំព័រ 34៖** កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ ជាភាសាអេស្ប៉ាញ
**ទំព័រ 35៖** ប្រវត្តិនៃគោលដៅដែលបានកំណត់របស់សហគមន៍
**ទំព័រ 36៖** ពាក្យ និងនិយមន័យដែលបានប្រើប្រាស់ជាញឹកញាប់
**ទំព័រ 37៖** រង្វាស់សម្រាប់ធ្វើការវាស់វែងលើភាពបន្ទាន់នៃកិច្ចការអាទិភាព
**ទំព័រ 38-41៖** សំណួរបើកអំពីកិច្ចការអាទិភាពនាពេលកន្លងមក (គួរតែប្រគល់ទៅកាន់ NKCDC ឬ IMPACT វិញ)

**ឧបសម្ព័ន្ធ (ទំព័រ 42-65)៖ កញ្ចប់បទបង្ហាញសម្រាប់ក្រុមរបស់អ្នក**

**អ្នកនឹងរកឃើញការណែនាំនៅគ្រប់កញ្ចប់ព័ត៌មានទាំងនេះ ដែលនឹងជួយកំណត់បរិបទនៃគម្រោង Kensington និងជួយគាំទ្រអ្នកក្នុងការសម្របសម្រួលកិច្ចប្រជុំជាមួយក្រុមរបស់អ្នក។ សូមទាក់ទងមកយើងខ្ញុំតាមរយៈ kensingtonplan@gmail.com សម្រាប់សំណួរ ឬសំណើនានាដែលអ្នកមាន ដើម្បីជួយគាំទ្រអ្នកក្នុងការសម្របសម្រួលកិច្ចប្រជុំ។**

# កញ្ចប់
# អ្នកសម្របសម្រួល

# ដំណើរការរៀបចំគម្រោង

**គោលដៅរួមរបស់យើងខ្ញុំមានដូចជា៖**

1. បង្កើតគម្រោងអ្នកជិតខាងមួយ ដែលទូលំទូលាយ ផ្តោតលើសហគមន៍ និងយល់ច្បាស់ពីទង្វិចសតិអារម្មណ៍។
2. សហការក្នុងការអនុវត្តន៍គម្រោងនេះ ជាមួយនឹងប្រជាពលរដ្ឋ អាជីវកម្ម រដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្មនានា។
3. បន្តស្វែងយល់ ទន្ទឹមនឹងពេលដែលយើងអភិវឌ្ឍធនធានចល័តទាំងឡាយ រហូតដល់ពេលដែលយើងបានសម្រេចគោលដៅដែលយើងបានកំណត់។

**ការពង្រឹងការយល់ដឹងបន្ថែម**

យើងខ្ញុំកំពុងអនុវត្តដំណើរការនេះដោយភ្ជាប់ជាមួយនិងស្វែងយល់អំពី "ក្រុម" ដែលមកពីគ្រប់សង្កាត់នៅទាំងអស់។ តើអ្វីទៅជាក្រុម?

Kensington មិនមែនជាក្រុមមនុស្សតែមួយដែលមានគំនិត ទំនៀមទម្លាប់ និងប្រវត្តិដូចគ្នានោះទេ។ ក្រុមនេះត្រូវបានបង្កើតឡើងដោយវប្បធម៌ ជាតិសាសន៍ និងក្រុមជាច្រើនដែលរស់នៅ ធ្វើការ និងកំសាន្តនៅក្នុង "ក្រុម" ផ្សេងៗគ្នា។

ក្រុមមនុស្សរបស់អ្នកអាចជា៖
·មិត្តភក្តិ គ្រួសារ អ្នកជិតខាង មិត្តរួមការងារនៅក្នុង Kensington
·ផ្នែកមួយនៃក្រុមដែលមានស្រាប់ដូចជា ក្រុម ក្លឹប ថ្នាក់ ឬក្រុមការងារនៅក្នុងសង្កាត់នៅ
·ក្រុមថ្មីមួយដែលអ្នកបង្រួបបង្រួមសម្រាប់ឱកាសនេះ។

អ្នកគឺជាអ្នកដឹកនាំដ៏ចាំបាច់ម្នាក់នៅក្នុងដំណើរការនៃការបង្រួបបង្រួមក្រុមរួមគ្នាសម្រាប់ការពិភាក្សាមួយ។ វាជារឿងសំខាន់ដែលអ្នកមានមនុស្សគ្រប់គ្រាន់នៅក្នុងបន្ទប់សម្រាប់ការសន្ទនាប្រកបដោយផលិតភាព ហើយមនុស្សដែលអ្នកអញ្ជើញមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយ Kensington ។ ដំណើរការរៀបចំផែនការធ្វើឱ្យមានកន្លែងសម្រាប់មនុស្សគ្រប់គ្នា ប៉ុន្តែអ្នករស់នៅក្នុង Kensington គឺជាចំណុចផ្តោតសំខាន់។

តាមរយៈការបង្រួបបង្រួមក្រុមផ្សេងៗគ្នានៅទូទាំង Kensington ហើយស្នើឱ្យក្រុមនីមួយៗកំណត់អាទិភាពសម្រាប់សង្កាត់របស់យើង សមាជិកសហគមន៍អាចកំណត់ថាតើពួកគេចង់ឱ្យអនាគតរបស់ Kensington ទៅជាយ៉ាងណា។ ព័ត៌មាននេះនឹងមានសារៈសំខាន់សម្រាប់ទីភ្នាក់ងារទីក្រុង និងរដ្ឋ និងអង្គការមិនរកប្រាក់ចំណេញដែលចង់វិនិយោគនៅ Kensington ជាមួយនឹងការផ្តល់មូលនិធិ ឬការបង្កើតកម្មវិធី។

# អំពីដំណើរការរៀបចំគម្រោង

### តើនរណាជាអ្នករៀបចំដំណើរការនេះ ហើយតើមានការផ្តល់មូនិធិដូចម្តេច?

NKCDC (Ruth និង Somerset) និង Impact Services (Allegheny និង Emerald) គឺជាអង្គការសហគមន៍ចំនួនពីរដែលប្តេជ្ញាធ្វើការរួមគ្នាដើម្បីជួយ Kensington ឱ្យរីកចម្រើន។

Impact Services និង NKCDC បានរួបរួមគ្នាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីធ្វើការសហការគ្នាដើម្បីជួយដល់សង្កាត់ ដោយប្រើប្រាស់បទពិសោធន៍ពីពេលកន្លងមកដែលដឹកនាំដំណើរការរៀបចំផែនការដើម្បីជួយពាំនាំមកនូវការផ្លាស់ប្តូរសម្រាប់ Kensington ។ បន្ទាប់ពីសវនាការរបស់ក្រុមប្រឹក្សាក្រុងនៅបឋមសិក្សា Elkin Primary School ក្នុងឆ្នាំ 2021 សម្ព័ន្ធនៃក្រុមសង្កាត់បានបន្តជួបប្រជុំដើម្បីកំណត់ និងសង្ខេបពីកង្វល់ និងដំណោះស្រាយរបស់ពួកគេ ដើម្បីបញ្ជូនទៅកាន់អភិបាលក្រុង Kenney នៅទីបំផុត។

Impact និង NKCDC គឺជាផ្នែកមួយនៃក្រុមសាលា Elkin School ហើយបានយល់ព្រមផ្តល់ការគាំទ្រ ដើម្បីឱ្យមនុស្សកាន់តែច្រើននៅទូទាំង Kensington អាចបានយល់ដឹងអំពីពួកគេ។ Impact និង NKCDC មានបទពិសោធន៍រៀបចំផែនការសហគមន៍ដោយមានការបញ្ចូលពីអ្នកស្រុករាប់រយនាក់នៅទូទាំងផ្នែកផ្សេងៗនៃ Kensington ។ កញ្ចប់សៀវភៅណែនាំ នេះគឺជាការខិតខំប្រឹងប្រែងដើម្បីនាំយកការងារធ្វើផែនការ និងការអនុវត្តរបស់យើងរួមគ្នា ដើម្បីបង្កើតដំណើរការសហការសម្រាប់សង្កាត់នេះ។

អ្នកអាចស្វែងរកគម្រោងមុនៗនៅលើគេហទំព័រ **kensingtonplan.org/resources**
គេហទំព័រដើមរបស់អង្គការទាំងពីរនេះ គឺ៖
**NKCDC.org**
**IMPACT.org**

ភាពជាអ្នកដឹកនាំរបស់ NKCDC និង Impact បានធ្វើការតាំងពីឆ្នាំមុនដើម្បីស្វែងរកមូលនិធិឯករាជ្យតាមរយៈអង្គការផ្តល់ជំនួយនៅទីក្រុង Philadelphia ដែលឥឡូវនេះនឹងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការរៀបចំគម្រោង Kensington ។ យើងបានរួបរួមគ្នាប្រមូលធនធានចាំបាច់ទាំងឡាយ។ យើងមិនមានកាតព្វកិច្ចនយោបាយនៅក្នុងដំណើរការនេះឡើយ។

# ប្រវត្តិនៃគោលដៅដែលបានកំណត់របស់សហគមន៍

អាទិភាពពីគម្រោង North of Lehigh Plan និង Heart of Kensington Plan ផ្តោតលើ៖

- **ពង្រឹងសុវត្ថិភាព និងកាត់បន្ថយទីផ្សារគ្រឿងញៀន។**
- **ការផ្លាស់ប្តូរគន្លងនៃលទ្ធផលសុខភាពអ្នកស្រុក។**
- **ការកែលម្អតំបន់លំនៅដ្ឋានសម្រាប់អ្នកស្រុក និងបង្កើតជម្រើសតំបន់លំនៅដ្ឋានដែលមានតម្លៃសមរម្យនៅលើប្រាក់ជួលដែលកាន់តែយ៉ាប់យ៉ឺន។**
- **កាត់បន្ថយដីទំនេរ និងការកែលម្អ/ការបង្កើន/ការធ្វើឱ្យមានទីវាលបៃតង**
- **ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីបង្កើនលទ្ធភាពទទួលបានទំនិញ និងសេវាកម្មចាំបាច់សម្រាប់អ្នកស្រុក។**
- **ការសម្របសម្រួលដល់ការកែលម្អផ្លូវ។**
- **វិនិយោគលើធនធានមនុស្ស ផ្តល់ឱកាសរីកចម្រើនទាំងចំណេះដឹងផ្ទាល់ខ្លួន និងវិជ្ជាជីវៈ។**

បន្ទាប់ពីការរួបរួមក្នុងការយល់ដឹងអំពីអ្នកស្រុកទាមទារឱ្យមានសកម្មភាពឆ្ពោះទៅរកសុខភាព និងសុវត្ថិភាពសហគមន៍ ការជួបប្រជុំរវាងអ្នកស្រុក ជាមួយក្រុមប្រឹក្សាក្រុងបានកើតឡើងនៅបឋមសិក្សា Elkin Elementary School ។ បញ្ជីនៃសកម្មភាពដែលអាចបានដែលបានមកពីកិច្ចប្រជុំនេះត្រូវបានផ្ញើទៅអភិបាល និងអភិបាលក្រុង Philadelphia ។ មានគំនិតមួយចំនួនទាក់ទងនឹងវិធីក្នុងការសម្រេចបាននូវគោលដៅ ប៉ុន្តែសរុបមក ការទាមទារទាំងនោះបានស្នើយ៉ាងច្បាស់លើចំណុចដូចខាងក្រោម៖

- **បញ្ឈប់ Kensington ពីការតាំងទីតាំងសម្រាប់ការប្រើប្រាស់គ្រឿងញៀន។ គាំទ្រដំណើរការបង្រួបបង្រួមសម្រាប់មនុស្សនៅខាងក្រៅសង្កាត់។**
- **សួនកម្សាន្ត និងមជ្ឈមណ្ឌលកម្សាន្ត ត្រូវបានកំណត់ និងអនុវត្តភ្លាមៗជាកន្លែងសុវត្ថិភាពសម្រាប់កុមារ និងក្រុមគ្រួសារ។**
- **បង្កើតយន្តការរាយការណ៍សង្ខេប។**
- **ផ្តល់លំនៅដ្ឋានសម្រាប់ទាំងអស់គ្នា។**
- **ផ្តល់ការព្យាបាលសម្រាប់ទាំងអស់គ្នា។**

# តារាងត្រួតពិនិត្យសម្រាប់កញ្ចប់កិច្ចប្រជុំ

**សូមប្រាកដថាអ្នកបានត្រៀមនូវសម្ភារចាំបាច់នានា មុនពេលកិច្ចប្រជុំចាប់ផ្តើម**

## កិច្ចប្រជុំផ្ទាល់

### សម្ភារចាំបាច់

- ទីកន្លែងដែលស្អាត និងមានសុវត្ថិភាពសម្រាប់ជួបជុំ
- កៅអី
- កុំព្យូទ័រដែលមានបើកស្លាយអ្នកសម្របសម្រួលរួចជាស្រេច
- ច្បាប់ចម្លងនៃតារាងកត់ត្រាការចូលរួម "កិច្ចព្រមព្រៀង" និង "ឧទាហរណ៍នៃបញ្ជីកិច្ចការអាទិភាព"
- អ្នកកត់ត្រា ដែលមានជាប់ខ្លួននូវ តារាង ឬគេហទំព័រ "របាយការណ៍ក្រុម" ដើម្បីឱ្យអ្នកអាចធ្វើការបញ្ចូលការកត់ត្រា។

### ជម្រើសខ្លះៗដើម្បីធ្វើឱ្យដំណើរការកាន់តែប្រសើរ...

- ភេសជ្ជៈដែលគ្មានជាតិអាល់កុល៖ ទឹក ទឹកផ្លែឈើ កាហ្វេ ឬតែ
- អាហារសម្រន់ដូចជានំស្រួយ នំ pretzel នំខេក ឬផ្លែឈើ ឬបន្លែផ្សេងៗ
- កន្សែងជូតដៃ
- សម ស្លាបព្រា និងសម្ភារទទួលទានអាហារ ប្រសិនបើត្រូវការ

## កិច្ចប្រជុំតាមអនឡាញ

- សាកសួរអ្នកចូលរួមអំពីឈ្មោះ អាសយដ្ឋាន ទូរស័ព្ទ អ៊ីមែល និងផ្នែកដែលចាប់អារម្មណ៍ជាមុន។ សូមពន្យល់ថា ការដែលមានកំណត់ត្រាអំពីអ្នកចូលរួមក្នុងក្រុមគឺមានសារៈសំខាន់ណាស់។
- ផ្ញើ "កិច្ចព្រមព្រៀង" និង"បញ្ជីឧទាហរណ៍នៃកិច្ចការអាទិភាព" ទៅកាន់អ្នកចូលរួមជាមុន។
- ពិនិត្យការតភ្ជាប់អ៊ីនធឺណេត និងសំឡេងរបស់អ្នក 20 នាទីមុនកិច្ចប្រជុំ ដូច្នេះអ្នកមានពេលនៅសល់ដើម្បីដោះស្រាយបញ្ហាណាមួយ។

# កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ

**យើងខ្ញុំត្រៀមខ្លួនសម្រាប់ស្វែងយល់ពីគំនិតថ្មីៗ។**
**យើងខ្ញុំត្រៀមខ្លួនសម្រាប់ស្វែងយល់ពីអ្នកដទៃ។**
**យើងខ្ញុំត្រៀមខ្លួនសម្រាប់តភ្ជាប់ មិនមែនសម្រាប់ឈ្លោះប្រកែកឡើយ។**

កិច្ចប្រជុំក្រុម មានគោលបំណងសម្រាប់ការសន្ទនា មិនមែនការប្រកែកគ្នាទេ។ គោលបំណងនៅក្នុងការសន្ទនា គឺការយល់ពីគ្នាទៅវិញទៅមក។

តាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំក្រុមនេះ ខ្ញុំនឹងតាំងចិត្តថា៖

- **ផ្តល់តម្លៃឱ្យគំនិតទាំងអស់។** ប្រាកដថាមានការចូលរួមពីមនុស្សគ្រប់គ្នា សូម្បីតែអ្នកដែលស្ងាត់ស្ងៀមបំផុតដើម្បីចូលរួមក្នុងការសន្ទនា។
- **ស្តាប់ដើម្បីយល់ពីអ្នកដទៃ។**
- **និយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ។** ប្រើប្រាស់ពាក្យ “ខ្ញុំ” មិនមែន “មនុស្ស” ឬ “យើង” ទេ។
- **មិននិយាយលើសលុប ឬបង្អាក់អ្នកដទៃ។** មេក្រូមួយ សំឡេងមួយ។

# ចាប់ផ្តើមនៅទីនេះ!

## សូមអរគុណដែលអ្នកបានចាប់អារម្មណ៍ក្នុងការរៀបចំ "ក្រុម" មួយសម្រាប់រៀបគម្រោងនាពេលអនាគត របស់ Kensington

### វិធីប្រើប្រាស់កញ្ចប់នេះ

1. **ពិនិត្យមើលព័ត៌មានដែលមាន** នៅក្នុងកញ្ចប់អ្នកសម្របសម្រួលនេះ។ យើងក៏មានរួមបញ្ចូលដូចជា៖
    - ស្លាយធ្វើបទបង្ហាញមួយដើម្បីណែនាំអំពីដំណើរការរៀបចំគម្រោង ទៅកាន់ក្រុមរបស់អ្នក
    - ឯកសារបន្ថែមស្រាប់ក្រុមរបស់អ្នក និង
    - ទម្រង់បែបបទរបាយការណ៍ក្រុម សម្រាប់បំពេញ និងដាក់ស្នើ ដើម្បីរក្សាជាកំណត់ត្រា លើអ្វីដែលអ្នកបាននិយាយ។
2. **ព្យាយាមឱ្យអ្នកដទៃបានចូលរួម។** ពន្យល់ពីដំណើរការរៀបចំផែនការ និងអញ្ជើញមនុស្សឱ្យចូលរួម។ សម្រេចចិត្តលើពេលវេលា និងទីកន្លែងងាយស្រួលដើម្បីជួបជុំ។ យើងស្នើឱ្យមានការប្រជុំពី 1 ទៅ 2 ម៉ោង។ នៅក្នុងកញ្ចប់នេះក៏រួមមានរបៀបវារៈមួយផងដែរ។
3. **ផ្សព្វផ្សាយអំពីកិច្ចប្រជុំរបស់អ្នក។** ប្រើប្រាស់ទម្រង់ខិតប័ណ្ណនៅខាងក្រោម ប្រសិនបើយល់ថាអាចជួយបាន។ ទាក់ទងទៅ NKCDC តាមរយៈលេខ 215-427-0350 ប្រសិនបើអ្នកត្រូវការច្បាប់ចម្លង។
4. **បន្សាំខ្លួនអ្នក** ជាមួយនឹងការធ្វើបទបង្ហាញក្រុម មុនពេលកិច្ចប្រជុំដោយប្រើប្រាស់ "កំណត់សម្គាល់អំពីបទបង្ហាញ" នៅខាងក្រោម។ សូមអានស្លាយឮៗដើម្បីឱ្យអ្នកគ្រប់គ្នា អាចឃើញ និងឮ បទបង្ហាញ។ ចំពោះផ្នែកកណ្តាលនៃស្លាយ (នៅខាងក្រោមទំព័រទី 3) មានដូចជា ព័ត៌មានសំខាន់អំពី កំណត់សម្គាល់អំពីបទបង្ហាញ ដែលអ្នកគួរតែអានឮៗ។
5. **ចម្លងឯកសារបន្ថែមនោះឱ្យបានច្រើន។** ទាក់ទងទៅ NKCDC តាមរយៈលេខ 215-427-0350 ឬ kensingtonplan@gmail.com ប្រសិនបើអ្នកត្រូវការជំនួយលើឯកសារនានា។
6. **ត្រូវការអាហារឬ?** សូមទាក់ទងទៅ Katsi Lozada តាមរយៈ kmiranda-lozada@nkcdc.org ឬ Erin Farrell តាមរយៈ efarrell@impactservices.org សម្រាប់ព័ត៌មានអំពីវិធីទទួលបានអាហារសម្រាប់កិច្ចប្រជុំរបស់អ្នក។
7. **រៀបចំកិច្ចប្រជុំរបស់អ្នក** ដោយប្រើប្រាស់របៀបវារៈដូចខាងក្រោម។សូមមើលគំនិតបន្ថែមទៀតសម្រាប់អ្នកសម្របសម្រួល សម្រាប់ព័ត៌មានរាយរង និងសំណើបន្ថែមទៀត។

# តើនៅក្នុងកញ្ចប់នេះមានអ្វីខ្លះ?

**ឯកសារសម្រាប់ជួយអ្នកក្នុងការរៀបចំដំណើរកិច្ចប្រជុំឱ្យបានជោគជ័យ**

- **កញ្ចប់ព័ត៌មាននេះ** សម្រាប់អ្នកក្នុងនាមជាអ្នកសម្របសម្រួល រួមទាំងរបៀបវារៈដែលបានស្នើសម្រាប់កិច្ចប្រជុំ និងកំណត់ត្រារបស់អ្នក សម្រាប់បទបង្ហាញក្រុមរបស់អ្នក
- **ការធ្វើបទបង្ហាញក្រុម** ដើម្បីណែនាំអំពីដំណើរការរៀបចំគម្រោង Kensington ទៅកាន់ក្រុមរបស់អ្នក
- **ឯកសារបន្ថែម** អ្នកអាចចែកបន្តនៅក្នុងកិច្ចប្រជុំក្រុមរបស់អ្នក
- បញ្ជីកិច្ចការអាទិភាព កិច្ចការអាទិភាពកន្លងមក សំណួរបើក និងតារាងគំនិតថ្មីៗ។
- យើងចង់ដឹងថាអ្នកណាខ្លះបានចូលរួមនៅក្នុងការសន្ទនា ហើយអ្នកបានពិភាក្សាអ្វីខ្លះ! សូមបំពេញតារាងខាងក្រោម។
    - តារាងកត់ត្រាការចូលរួម តារាងវាយតម្លៃកិច្ចការអាទិភាពកន្លងមក តារាងសំណួរបើក និងតារាងគំនិតថ្មីៗ។
- អ្នកអាចត្រឡប់សន្លឹកទាំងអស់នេះដែលបានរាយបញ្ជីខាងលើតាមវិធីងាយស្រួលណាមួយ៖
    - ដោយផ្ទាល់ ឬដោយផ្ញើសំបុត្រ ទៅកាន់ Att: Katsi Lozada NKCDC នៅ 2771 Ruth Street, Philadelphia, PA 19134
    - ដោយការថតរូប (ច្បាស់ល្អ) ហើយផ្ញើទៅកាន់  IMPACT **Erin Farrell efarrell@impactservices.org**, NKCDC **Katsi Lozada Kmiranda-lozada@nkcdc.org** ឬ **kensingtonplan@gmail.com**.
- **គំនិតបន្ថែមសម្រាប់អ្នកសម្របសម្រួល**
- **កាតកាដូ** ដើម្បីទិញសម្ភារកិច្ចប្រជុំដូចជា ប៊ិច ក្រដាស ។ល។
- **ទម្រង់សម្រាប់ខិត្តប័ណ្ណ** (ទំព័របន្ទាប់) ដែលអ្នកអាចប្រើប្រាស់បានដើម្បីផ្សព្វផ្សាយ។

# កញ្ចប់
# ធនធាន
# បន្ថែម

# ការចូលរួមក្នុងសហគមន៍ 101

## ការលើកទឹកចិត្ត នៅពេលដែលអ្នករៀបចំសម្រាប់ ការប្រជុំជាក្រុមរបស់អ្នក!

### ការផ្សព្វផ្សាយទៅកាន់សហគមន៍របស់អ្នក

- ការផ្សព្វផ្សាយគឺដូចជាការស្ទូចត្រី អ្នកមិនអាចដឹងមុនទេថាអ្នកនឹងស្ទូចបានអ្វី។
- ភាសាកាយវិការគឺជាទម្រង់ទីមួយ នៃការប្រាស្រ័យទាក់ទង។
- ការព្យាយាម អាចនឹងបានសម្រេច! ប្រសិនបើដំបូង អ្នកមិនបានជោគជ័យទេ សូមព្យាយាមវិធីផ្សេងទៀត ប៉ុន្តែសូមកុំបោះបង់។
- ការតាមដានបន្តជាមួយមនុស្ស បង្កើតបានជាទំនាក់ទំនងដែលស៊ីជម្រៅ និងយូរអង្វែង។

### ការធ្វើជាអ្នករៀបចំកិច្ចប្រជុំមួយ

- ភាពរួសរាយ គឺមានភាពទាក់ទាញដូចជាទឹកឃ្មុំ។
- យល់ដឹងអំពីឯកសាររបស់អ្នក និងអ្នកចូលរួមរបស់អ្នក។
- ការស្តាប់ដោយយកចិត្តទុកដាក់អាចធ្វើឱ្យកាន់តែប្រសើរ!

### ការធ្វើជាគម្រូ

- សកម្មភាពរបស់អ្នកអាចជំរុញឱ្យអ្នកដទៃ ដាក់គោលដៅ ព្យាយាម រៀនសូត្រ អនុវត្ត និងធ្វើកិច្ចការផ្សេងៗជាច្រើន។
- អ្នកមានថាមពលក្នុងការបង្វែររឿងអវិជ្ជមានឱ្យទៅជាវិជ្ជមានវិញបាន។
- នៅក្នុងពាក្យថាក្រុម គឺមិនមែនមានតែ “ខ្ញុំ” ម្នាក់ឯងទេ។ ប្រសិនបើដួលមួយ គឺដួលទាំងអស់គ្នា។

# មកកាន់តុ

## យើងសាកស្រមៃថាដំណើរការរៀបចំគម្រោង Kensington គឺជាអាហារចម្រុះមួយពេល ដែលមនុស្សគ្រប់គ្នាយកអាហារល្អបំផុតរៀងៗខ្លួនមកជាមួយ។



# តាមដានបន្តបន្ទាប់

## គឺជាវិធីមួយដែលអាចកំណត់បរិយាកាសវិជ្ជមាន សម្រាប់ការសន្ទនាដែលអំណោយផលមួយ

អារម្មណ៍របស់យើងតែងតែស្ថិតនៅជាមួយយើង។ ពេលខ្លះអារម្មណ៍នោះចូលមកក្នុងជីវិតយើងតាមរបៀបដែលយើងនឹកស្មានមិនដល់។ លំហាត់នេះគឺជាវិធីមួយសម្រាប់មនុស្សគ្រប់គ្នាដែលមានវត្តមាននៅក្នុងបន្ទប់ដើម្បីទទួលស្គាល់អារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ និងសម្រាប់អ្នកដទៃឱ្យយល់ថាពួកគេស្ថិតនៅស្ថានភាពបែបណា។

មានសំណួរសាមញ្ញចំនួនបួនសម្រាប់មនុស្សសួរគ្នាជាគូ ឬក្រុមតូចៗ៖

### 1. តើអ្នកមានអារម្មណ៍យ៉ាងណាដែរ?

នេះគួរតែជាចម្លើយមួយ ឬពីរពាក្យ មិនមែនជាសាច់រឿងទេ។ អ្នកមិនចាំបាច់ពន្យល់អ្វីទេ។ ប៉ុន្តែអ្នកត្រូវប្រើពាក្យបង្ហាញអារម្មណ៍។ ពាក្យថា "ល្អ" មិនទាន់ពិពណ៌នាគ្រប់គ្រាន់ទេ។ សាកល្បងពាក្យដូចជា ចង់ដឹងចង់ឃើញ បារម្ភ ធូរស្រាល សង្ឃឹម...

### 2. តើគោលដៅរបស់អ្នកសម្រាប់ថ្ងៃនេះមានអ្វីខ្លះ?

បទពិសោធន៍ស្ត្រេសអាចធ្វើឱ្យយើងពិបាកគិតអំពីអនាគត។ ជាថ្មីម្តងទៀត ចម្លើយខ្លីបំផុតគឺជាអ្វីដែលអ្នកត្រូវផ្តល់។

### 3. តើអ្នកណាខ្លះអាចជួយគាំទ្រដល់អ្នក?

ភាពតានតឹង និងទង្គិចសតិអារម្មណ៍ក៏បំបែកយើងពីអ្នកដទៃដែរ។ ប្រសិនបើនរណាម្នាក់ដាក់ឈ្មោះអ្នកថាជាមនុស្សម្នាក់ដែលអាចគាំទ្រពួកគេ អ្នកអាចនិយាយថា "ខ្ញុំនឹងគាំទ្រអ្នក"។

### 4. តើថ្ងៃនេះអ្នកបានមើលថែខ្លួនឯងដូចម្តេចខ្លះ?

# ចំណុចដែលត្រូវពិចារណា

**សួរខ្លួនអ្នក និងអ្នកដទៃ...**

- នៅក្នុងដំណើរការនៃការផ្លាស់ប្តូរសង្កាត់ តើតួនាទីរបស់អ្នកអាចជាអ្វី?
- តើអ្នកអាចវាយតម្លៃសារៈសំខាន់ ឬកម្រិតនៃភាពបន្ទាន់នៃបញ្ហាដែលអ្នកបានកំណត់ដោយប្រើប្រាស់លេខដែលចាប់ផ្តើមនៅ "1" ជាបន្ទាន់បំផុតដែរឬទេ?



# ការព្រាងសំណួរ ផ្នែកទី 1

## សំណួរខ្លះៗដើម្បីនាំអ្នកចូលរួមឱ្យចាប់ផ្តើមពិភាក្សាគ្នា

- តើសង្កាត់មានចំណុចខ្លាំងអ្វីខ្លះដែលត្រូវពង្រឹង?
- តើកន្លែងណាដែលអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពបំផុតនៅក្នុងសង្កាត់?
- តើអ្វីជាបញ្ហាប្រឈមធំបំផុតនៅក្នុងសង្កាត់ ហើយតើបញ្ហាប្រឈមទាំងនោះបានផ្លាស់ប្តូរយ៉ាងដូចម្តេចក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ?
- តើអ្នកគិតថាអ្វីដែលរារាំងការផ្លាស់ប្តូរជាវិជ្ជមានយូរអង្វែងនៅ Kensington?

# ពាក្យដែលបានប្រើប្រាស់ជាញឹកញាប់

## ឃ្លាមួយចំនួនដែលអ្នកអាចនឹងឮនៅក្នុងការសន្ទនាអំពីអ្នកជិតខាង

**លំនៅដ្ឋានតម្លៃរម្យ**—តំបន់លំនៅដ្ឋានដែលមិនតម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកជួលចំណាយលើសពី 30 ភាគរយនៃប្រាក់ចំណូលសរុបក្នុងគ្រួសាររបស់ពួកគេ ដែលរួមទាំងការចំណាយលើការប្រើប្រាស់នានាក្នុងផ្ទះផងដែរ។

**គម្រោង Anchor** —ជាគម្រោងទាំងឡាយណាដែលនឹងមានឥទ្ធិពលយ៉ាងធំធេងជាវិជ្ជមានលើតំបន់ដែលនៅជុំវិញ។

**វិជ្ជាពលរដ្ឋ**—ក្រុមអ្នកស្រុកដែលបានរៀបចំដែលមានគោលដៅផ្លូវការគឺដើម្បីកែលម្អសង្កាត់តាមរយៈការងារស្ម័គ្រចិត្តដោយសមាជិករបស់ខ្លួន។

**ការអភិវឌ្ឍន៍**—ដំណើរការនៃការបំប្លែងដីទៅជាគោលបំណងថ្មីដោយការសាងសង់ ឬប្រើប្រាស់ធនធានរបស់ទីតាំងនោះ។

**ផ្លូវនៃសុខភាព និងសុខុមាលភាព**—Impact Services និង NKCDC កំពុងសម្របសម្រួលគម្រោងនៅតាមបណ្ដោយ Kensington និង Indiana Avenues ដើម្បីដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពដែលកំណត់ដោយសហគមន៍។

**កាត់បន្ថយទីផ្សារគ្រឿងញៀន**—ធ្វើការដើម្បីកាត់បន្ថយបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន។

**NAC**—អង្គការ Neighborhood Advisory Committee (NAC) ជួយដល់អ្នកស្រុកឱ្យបានស្វែងយល់បន្ថែមអំពីកម្មវិធី City ដែលអាចផ្ដល់អត្ថប្រយោជន៍ដល់ពួកគេ

**ក្រុម**—ក្រុមនៃមនុស្សដែលបានយល់ព្រមជួបគ្នាដើម្បីរៀបចំផែនការអនាគតរបស់ Kensington!

**កត្តាសង្គមដែលជះឥទ្ធិពលលើសុខភាព**—កត្តាដែលមិនមែនវេជ្ជសាស្ត្រ ដែលប៉ះពាល់ដល់សុខភាពមនុស្សក្នុងកម្រិតធ្ងន់ធ្ងរ ដូចជាផ្នែកតំបន់លំនៅដ្ឋាន អាហារជីវជាតិ ការអប់រំ ការមានការងារធ្វើ ការដឹកជញ្ជូន ការថែទាំកុមារ និងផ្សេងទៀត។

**ការកំណត់នៃតំបន់**—បទប្បញ្ញត្តិរដ្ឋ ឬមូលដ្ឋានដែលគ្រប់គ្រងពីវិធីដែលអចលនទ្រព្យអាចប្រើប្រាស់បាននៅក្នុងទីកន្លែងផ្សេងៗគ្នា។

# ការប៉ះពាល់នៃទង្វិចសតិអារម្មណ៍

## ស្ថានភាពអ្នកជិតខាងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពបុគ្គល និងគ្រួសារ

### មុន




ទីតាំងបច្ចុប្បន្នរបស់យើង

ទិសដៅដែលយើងកំពុងតែឆ្ពោះទៅ



# កត្តាសង្គមដែលជះឥទ្ធិពលលើសុខភាព

## ចំណុចពិសេសដែលអាចធ្វើឱ្យសុខភាពសហគមន៍កាន់តែប្រសើរ

### ការអប់រំ

- សាលារៀនស្អាត សុវត្ថិភាព
- ជំនួយសិក្សាសម្រាប់គ្រប់គ្នា
- ការអប់រំសម្រាប់មនុស្សពេញវ័យ
- អាចចូលរៀននៅមហាវិទ្យាល័យ និងសាកលវិទ្យាល័យ





### ឱកាសផ្នែកសេដ្ឋកិច្ច

- វគ្គបណ្តុះបណ្តាលការងារ
- ការស្វែងរកអាជីព
- ការងារបន្ថែមទៀត
- ឱកាសការងារប្រាក់ខែខ្ពស់



### ការទទួលបានការថែទាំសុខាភាព

- ទទួលបានធានារ៉ាប់រងសុខភាពទទួលបានការថែទាំវេជ្ជសាស្ត្រដូចគ្នា
- ទទួលបានជំនួយសុខភាពផ្លូវចិត្ត
- អាហារសុខភាព

### បរិស្ថានជុំវិញតំបន់

- សួន & សួនកុមារ សួនច្បារ
- ដី & ផ្ទះទំនេរ
- ផ្ទះដែលត្រូវការជួសជុល
- ការអភិវឌ្ឍន៍ (ផ្ទះតម្លៃសមរម្យ)
- សាលារៀន
- វិហារគ្រិស្ត
- អាជីវកម្ម



### សហគមន៍

- តំបន់អ្នកដឹកនាំ
- ទំនាក់ទំនងវេជ្ជមានជាមួយអ្នកជិតខាង
- អ្នកស្រុក
- គ្រួសារ



# ឯកសារបន្ថែម

# ការផ្លាស់ប្តូរកំពុងតែខិតជិតមកដល់ KENSINGTON



# មានតម្រូវការចំពោះគំនិតរបស់អ្នក

អ្នករៀបចំ ______________________

សូមអញ្ជើញអ្នកចូលរួមក្នុងកិច្ចប្រជុំ ដើម្បីជួយកំណត់កិច្ចការអាទិភាព សម្រាប់សហគមន៍របស់អ្នក

កាលបរិច្ឆេទ ______________________

ទីតាំង ______________________

ទំនាក់ទំនង ______________________

**តោះយើងរៀបចំគម្រោង KENSINGTON ទាំងអស់គ្នា**

KENSINGTONPLAN.ORG

# រៀបរារៈកិច្ចប្រជុំក្រុម

**លំដាប់លំដោយដែលបានស្នើ សម្រាប់ការសន្ទនារយៈពេលចន្លោះពីមួយម៉ោង ទៅពីរម៉ោង**



## កិច្ចស្វាគមន៍ & សេចក្ដីផ្ដើម

**5 ទៅ 10 នាទី**

សូមស្វាគមន៍អ្នកទាំងអស់គ្នា។ សូមឱ្យគ្រប់គ្នាបំពេញតារាង "អ្នកចូលរួម" ។ អញ្ជើញមនុស្សម្នាក់ៗឱ្យណែនាំខ្លួនឯង និងចំណុចដែលនាំពួកគេចូលរួមក្នុងការសន្ទនា។ ប្រសិនបើអ្នកមានក្រុមធំ សូមអញ្ជើញពួកគេឱ្យចែករំលែកជាក្រុមតូចៗ។



## ចាប់ផ្ដើមការសន្ទនា

**10 ទៅ 15 នាទី**

ពន្យល់ពីដំណើរការរៀបចំគម្រោង។ ប្រើការបង្ហាញស្លាយ និងកំណត់ចំណាំខាងក្រោម។ ឆ្លើយសំណួរ ឬសរសេរ ដើម្បីឱ្យអ្នកដទៃអាចឆ្លើយនៅពេលក្រោយផងដែរ។

ដើម្បីធ្វើការសន្ទនាដោយមានផ្លែផ្កា ប្រសិនបើអ្នកគ្រប់គ្នានៅក្នុងបន្ទប់អាចយល់ស្រប អំពីរបៀបនិយាយគ្នាទៅវិញទៅមក នោះពិតជាមានអត្ថប្រយោជន៍។ យើងបានរាយការផ្ដល់យោបល់ចំនួនបួននៅលើឯកសារ "កិច្ចព្រមព្រៀង" ប៉ុន្តែក្រុមរបស់អ្នកអាចនឹងមកជាមួយអ្នកដទៃ។ ហើយក៏អាចមានប្រយោជន៍ក្នុងការឱ្យអ្នកចូលរួមជ្រើសរើសកិច្ចព្រមព្រៀងដែលពួកគេនឹងចងចាំក្នុងអំឡុងពេលសន្ទនា។

ចាត់តាំងនរណាម្នាក់ឱ្យកត់ត្រា! អ្នកអាចកត់ត្រានៅលើតារាងដែលបានផ្ដល់ ហើយបញ្ជូនមកវិញដោយផ្ទាល់ ឬតាមសំបុត្រ **Att: Katsi Lozada NKCDC at 2771 Ruth Street, Philadelphia, PA 19134** ។ ឬអ្នកអាចថតរូប (ច្បាស់ល្អ) ហើយផ្ញើអ៊ីម៉ែលទៅកាន់ IMPACT **Erin Farrell efarrell@impactservices.org**, NKCDC **Katsi Lozada Kmiranda-lozada@nkcdc.org** ឬ **kensingtonplan@gmail.com** អ្នកអាចបំពេញបែបបគេហទំព័រនៅ

# រៀបវារៈកិច្ចប្រជុំក្រុម (បន្ត)



## ការសន្ទនា

**30 ទៅ 60 នាទី**

ជាដំបូង សូមថ្លឹងថ្លែងលើអាទិភាពពី "បញ្ជីឧទាហរណ៍នៃកិច្ចការអាទិភាព"។ គូសសម្គាល់កិច្ចការអាទិភាពដែលក្រុមរបស់អ្នកយល់ព្រម។ គូសចោលលើអ្វីដែលអ្នកមិនយល់ស្រប។ បន្ទាប់មក បន្ថែមអាទិភាពបន្ថែម និងការណែនាំបន្ថែមសម្រាប់សកម្មភាពនៅលើតារាងខាងក្រោម។

ប្រើតារាងបន្ថែមដោយសេរី។ ប៉ុន្តែបើកាន់តែល្អ យើងមិនចង់បានបញ្ជីបោកគក់ទេ។ យើងចង់បានអាទិភាពកម្រិតកំពូលមួយចំនួនសម្រាប់សង្កាត់ និងវិធីជាក់ស្តែងដើម្បីដោះស្រាយបញ្ហាទាំងនោះ។



## ការសន្ទនាបិទ

**10 ទៅ 15 នាទី**

ចាប់ផ្តើមបញ្ចប់ការពិភាក្សា។ រកមើលប្រធានបទសំខាន់ៗ និងចំណុចនៃកិច្ចព្រមព្រៀង។ កត់សម្គាល់ការមិនចុះសម្រុងគ្នា។ ត្រឡប់ទៅគំនិតពីមុននៅក្នុងការសន្ទនាដែលសមនឹងការពិភាក្សាបន្ថែមទៀត។



## ចែករំលែក និងថ្លែងអំណរគុណ

**5 ទៅ 10 នាទី**

អញ្ជើញមនុស្សឱ្យចែករំលែកគំនិតវិជ្ជមាន ឬការបញ្ជាក់អំពីគ្នាទៅវិញទៅមក ឬការសន្ទនាដែលអ្នកទើបតែមាន។ ថ្លែងអំណរគុណដល់អ្នកគ្រប់គ្នា។

# កំណត់សម្គាល់នៃបទបង្ហាញ

ការអាននូវអ្វីដែលនៅលើអេក្រង់សម្រាប់អ្នកដែលមិនចូលចិត្តអាន ឬមើលមិនឃើញអេក្រង់បាន នោះគឺជាការល្អមយយ។ ឆ្ពោះទៅផ្នែកកណ្តាលនៃការបញ្ចាំងស្លាយ មានកំណត់ចំណាំ និងការណែនាំបន្ថែមនៅទីនេះ ដែលមិនមាននៅលើស្លាយ។




អ្នកអាចមានស្លាយនេះនៅលើអេក្រង់កំឡុងពេល**ស្វាគមន៍ និងការណែនាំ**។




**ចាប់ផ្តើមការសន្ទនា**នៅលើស្លាយនេះ។ វាជាការល្អក្នុងការអាននូវអ្វីដែលនៅលើអេក្រង់សម្រាប់អ្នកដែលមិនចូលចិត្តអាន ឬមើលមិនឃើញអេក្រង់។




មនុស្សមួយចំនួននៅក្នុងក្រុមរបស់អ្នកប្រហែលជាចងចាំគំនិតផ្តួចផ្តើមទីក្រុងទាំងនេះ។ អត្ថបទរបស់វេជ្ជបណ្ឌិត *Bill McKinney* សម្រាប់ *WHYY* "ប្រវត្តិសាស្ត្រកំពុងកើតឡើងម្តងទៀតនៅ *Kensington*" គឺជាការចាប់ផ្តើមដ៏ល្អសម្រាប់ព័ត៌មានបន្ថែម។ ចូលទៅកាន់ ***kensingtonplan.org/resources*** សម្រាប់តំណគេហទំព័រ។




វិធីសាស្ត្រម្តងមួយតំបន់ នៃ 24th District Capt. Charles Vogt បានចាប់ផ្តើមនៅក្នុងឆ្នាំ 2012។

# កំណត់សម្គាល់នៃបទបង្ហាញ (បន្ត)




ទីក្រុងនេះបានសម្អាតជំរុំដ៏ធំមួយពីផ្លូវ Conrail នៅជិតផ្លូវ Gurney ក្នុងឆ្នាំ 2017




ដំណោះស្រាយទាំងនេះខ្វះធនធាន និងជំនាញគ្រប់គ្រាន់ ខ្វះការបញ្ចូលសហគមន៍ និងមិនបានដោះស្រាយបញ្ហាដែលទាក់ទងគ្នាទៅវិញទៅមក។




ប៉ុន្តែសហគមន៍ Kensington មានភាពធន់៖




ការសម្អាតនៅក្នុងតំបន់ដែលអ្នករស់នៅ




កិច្ចប្រជុំសហគមន៍

# កំណត់សម្គាល់នៃបទបង្ហាញ (បន្ត)




ផ្លូវសម្រាប់លេង និងការជប់លាងនៅតាមតំបន់

សួរក្រុមសម្រាប់ឧទាហរណ៍ផ្សេងទៀតអំពីរបៀបដែលអ្នកជិតខាង *Kensington* បានពង្រឹងសហគមន៍របស់យើង។




ឥឡូវនេះយើងបានឈានមកដល់ចំណុចមួយដែល ការផ្លាស់ប្តូរពិតប្រាកដគឺអាចទៅរួច




រដ្ឋនេះកំពុងតែវិនិយោគលើ Kensington




ទីក្រុងនេះកំពុងតែវិនិយោគលើ Kensington




ហើយសហគមន៍កំពុងរួមគ្នាដើម្បីសម្រេចកិច្ចការនានា។ នេះគឺជារូបថតរបស់ Philadelphia Inquirer ពីការតវ៉ាដែលធ្វើឱ្យចំណត Somerset El បើកម្តងទៀតក្នុងខែមីនា ឆ្នាំ 2021។

# កំណត់សម្គាល់នៃបទបង្ហាញ (បន្ត)




កាលពីឆ្នាំមុន អ្នកជិតខាង អង្គការមិនរកប្រាក់ចំណេញ និង ភ្នាក់ងារទីក្រុងបានធ្វើការរួមគ្នាដើម្បីបង្កើតកន្លែងលេង ប្រកបដោយសុវត្ថិភាពនៅទីលាន McPherson Square សួនកុមារ Hissey Playground និងសួន Harrowgate Park ។




Impact Services និង NKCDC កំពុងធ្វើការរួមគ្នាលើគម្រោងនៅ Kensington និង Indiana Avenues ។ ចក្ខុវិស័យរបស់ពួកគេសម្រាប់ "ផ្លូវនៃសុខភាព និង សុខុមាលភាព" កើតចេញពីការសន្ទនាផែនការសហគមន៍ ដូចអ្វីដែលយើងកំពុងមានសព្វថ្ងៃនេះ។




នៅឆ្នាំ 2021 ក្រុមប្រឹក្សាក្រុងមានសវនាការនៅសាលា Lewis Elkin Middle School ។

**ក្រោមយមក ក្រុមចម្រុះនៃសង្កាត់ បានសង្ខេបពីកង្វល់ និងដំណោះស្រាយដែលបានពីកិច្ចប្រជុំ និងបានបញ្ជូនសេចក្ដីសង្ខេបទាំងនេះសាកិច្ចអំពាវនាវទៅកាន់អភិបាលក្រុង Kenney។**

ក្រោយមក ក្រុមចម្រុះនៃសង្កាត់បានសង្ខេបពីកង្វល់ និង ដំណោះស្រាយដែលប្រជាពលរដ្ឋបាននិយាយនៅក្នុងសវនាការ ហើយបានបញ្ជូនសេចក្ដីសង្ខេបទៅអភិបាលក្រុង Kenney ។ ក្រុមនេះបានបន្តការប្រជុំ និងបន្ថែមសមាជិកថ្មី ហើយបានកែប្រែការអំពាវនាវរបស់ខ្លួនឱ្យធ្វើសកម្មភាព សម្រាប់រដ្ឋបាល Kenney ។

# កំណត់សម្គាល់នៃបទបង្ហាញ (បន្ត)




Noelle Foizen មកពីអង្គភាពឆ្លើយតប Opioid របស់ Philadelphia និយាយថា ការអំពាវនាវឱ្យមានសកម្មភាពនេះគឺជាអ្វីដែលនាំឱ្យទីក្រុងដើម្បីលះបង់មូលនិធិទូទាត់ Opioid មួយចំនួនរបស់ខ្លួនដល់ឧទ្យាន Kensington សាលារៀន ការជួសជុលផ្ទះ ការទប់ស្កាត់ការរឹបអូស និងជំនួយការជួលផងដែរ។




កិច្ចប្រជុំនេះមានគោលដៅចំនួនពីរ៖




1. ដើម្បីទទួលបានមតិកែលម្អរបស់អ្នកអំពីអាទិភាពទាំងនេះដែលចេញពីកិច្ចប្រជុំសាលា Elkin School ។




2. ដើម្បីស្តាប់អំពីកិច្ចការអាទិភាព និងការផ្តល់យោបល់របស់អ្នកសម្រាប់ Kensington




ចែកបន្តនូវឯកសារបន្ថែមអំពី "កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ"

មុនពេលយើងចាប់ផ្តើមនិយាយ វាមានប្រយោជន៍ក្នុងការយល់ស្របអំពីប្រធានបទនៃការសន្ទនានេះ...

# ចំណុចដែលត្រូវពិចារណា អំឡុងពេលរាយបញ្ជីកិច្ចការអាទិភាព

នៅក្នុងដំណើរការនៃការផ្លាស់ប្តូរសង្កាត់ តើតួនាទីរបស់អ្នកអាចជាអ្វី?

តើអ្នកអាចវាយតម្លៃសារៈសំខាន់ ឬកម្រិតនៃភាពបន្ទាន់នៃបញ្ហាដែលអ្នកបាន កំណត់ដោយប្រើលេខដែលចាប់ផ្តើមនៅលេខ "1" ជាបន្ទាន់បំផុតបានទេ?





# កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ

**យើងខ្ញុំត្រៀមខ្លួនសម្រាប់ស្វែងយល់ពីគំនិតថ្មីៗ។**
**យើងខ្ញុំត្រៀមខ្លួនសម្រាប់ស្វែងយល់ពីអ្នកដទៃ។**
**យើងខ្ញុំត្រៀមខ្លួនសម្រាប់តភ្ជាប់ មិនមែនសម្រាប់ឈ្លោះប្រកែកឡើយ។**

កិច្ចប្រជុំក្រុម មានគោលបំណងសម្រាប់ការសន្ទនា មិនមែនការប្រកែកគ្នាទេ។ គោលបំណងនៅក្នុងការសន្ទនា គឺការយល់ពីគ្នាទៅវិញទៅមក។

តាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំក្រុមនេះ ខ្ញុំនឹងតាំងចិត្តថា៖

- ផ្តល់តម្លៃឱ្យគំនិតទាំងអស់។ ប្រាកដថាមានការចូលរួមពីមនុស្សគ្រប់គ្នា សូម្បីតែអ្នកដែលស្ងាត់ស្ងៀមបំផុតដើម្បីចូលរួមក្នុងការសន្ទនា។
- ស្តាប់ដើម្បីយល់ពីអ្នកដទៃ។
- និយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ។ ប្រើប្រាស់ពាក្យ “ខ្ញុំ” មិនមែន “មនុស្ស” ឬ “យើង” ទេ។
- មិននិយាយលើសលុប ឬបង្អាក់អ្នកដទៃ។ មេក្រូមួយ សំឡេងមួយ។

# តារាងកត់ត្រាការចូលរួម

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត ________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- ☐ ទីវាលបៃតង
- ☐ ការរៀបចំគម្រោងសហគមន៍
- ☐ ផ្នែកតំបន់លំនៅឋាន
- ☐ អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត ________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- ☐ ទីវាលបៃតង
- ☐ ការរៀបចំគម្រោងសហគមន៍
- ☐ ផ្នែកតំបន់លំនៅឋាន
- ☐ អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត ________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- ☐ ទីវាលបៃតង
- ☐ ការរៀបចំគម្រោងសហគមន៍
- ☐ ផ្នែកតំបន់លំនៅឋាន
- ☐ អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត ________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- ☐ ទីវាលបៃតង
- ☐ ការរៀបចំគម្រោងសហគមន៍
- ☐ ផ្នែកតំបន់លំនៅឋាន
- ☐ អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត ________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- ☐ ទីវាលបៃតង
- ☐ ការរៀបចំគម្រោងសហគមន៍
- ☐ ផ្នែកតំបន់លំនៅឋាន
- ☐ អាហារ

# តារាងកត់ត្រាការចូលរួម

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត __________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- [ ] ទីវាលបៃតង
- [ ] ការរៀបចំគម្រោងសហគមន៍
- [ ] ផ្នែកតំបន់លំនៅឋាន
- [ ] អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត __________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- [ ] ទីវាលបៃតង
- [ ] ការរៀបចំគម្រោងសហគមន៍
- [ ] ផ្នែកតំបន់លំនៅឋាន
- [ ] អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត __________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- [ ] ទីវាលបៃតង
- [ ] ការរៀបចំគម្រោងសហគមន៍
- [ ] ផ្នែកតំបន់លំនៅឋាន
- [ ] អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត __________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- [ ] ទីវាលបៃតង
- [ ] ការរៀបចំគម្រោងសហគមន៍
- [ ] ផ្នែកតំបន់លំនៅឋាន
- [ ] អាហារ

ឈ្មោះ៖ ______________________
អាសយដ្ឋាន៖ ______________________
អ៊ីម៉ែល៖ ______________________
លេខទូរស័ព្ទ៖ ______________________
ទំហំអាវយឺត __________

## ចំណាប់អារម្មណ៍បច្ចុប្បន្ន?

- [ ] ទីវាលបៃតង
- [ ] ការរៀបចំគម្រោងសហគមន៍
- [ ] ផ្នែកតំបន់លំនៅឋាន
- [ ] អាហារ

# សម្រាប់ព័ត៌មានបន្ថែម

## យើងខ្ញុំនៅទីនេះដើម្បីជួយគាំទ្រដល់អ្នក

សម្រាប់ព័ត៌មានផ្សេងៗបន្ថែមអំពីដំណើរការរៀបចំផែនការ Kensington សូមចូលទៅកាន់ kensingtonplan.org ។ គេហទំព័រនោះរួមមានដូចជា៖

- **ប្រវត្តិ**នៃរបៀបដែលផែនការបានចាប់ផ្តើម (kensingtonplan.org/about)
- **ចក្ខុវិស័យ**សម្រាប់ដំណើរការទូលំទូលាយ ដែលជំរុញដោយសហគមន៍ ដែលផ្តល់ព័ត៌មានអំពីទង្គីចសតិអារម្មណ៍អាចមានទម្រង់ដូច (kensingtonplan.org/vision)
- **តំណគេហទំព័រ**ទៅកាន់ព័ត៌មានបន្ថែម (kensingtonplan.org/resources)

សម្រាប់ការបង្ហាញបន្ថែម និងគំនិតផ្សព្វផ្សាយ សូមមើល គំនិតបន្ថែមសម្រាប់អ្នកសម្របសម្រួល នៅក្នុងកញ្ចប់នេះ។

សូមទាក់ទងទៅកាន់ IMPACT **Erin Farrell efarrell@impactservices.org, NKCDC Katsi Lozada Kmiranda-lozada@nkcdc.org ឬ** ប្រសិនបើអ្នកមានសំណួរបន្ទាន់ យើងនឹងព្យាយាមឱ្យអស់ពីលទ្ធភាពដើម្បីជួយគាំទ្រដល់អ្នក។

**សូមអរគុណសម្រាប់ការជួយរបស់អ្នក ក្នុងការគិតប្រមើល**
**អំពីអនាគតថ្មីមួយសម្រាប់សហគមន៍ Kensington**

## ការផ្លាស់ប្តូរកំពុងតែខិតជិតមកដល់ KENSINGTON



# មានតម្រូវការចំពោះគំនិតរបស់អ្នក

អ្នករៀបចំ ______________________

សូមអញ្ជើញអ្នកចូលរួមក្នុងកិច្ចប្រជុំ ដើម្បីជួយកំណត់
កិច្ចការអាទិភាព សម្រាប់សហគមន៍របស់អ្នក

កាលបរិច្ឆេទ ______________________

ទីកន្លែង ______________________

ទំនាក់ទំនង ______________________

**តោះយើងរៀបចំគម្រោង KENSINGTON ទាំងអស់គ្នា**
KENSINGTONPLAN.ORG



# កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ

## យើងខ្ញុំត្រៀមខ្លួនសម្រាប់ស្វែងយល់ពីគំនិតថ្មីៗ។
## យើងខ្ញុំត្រៀមខ្លួនសម្រាប់ស្វែងយល់ពីអ្នកដទៃ។
## យើងខ្ញុំត្រៀមខ្លួនសម្រាប់តភ្ជាប់ មិនមែនសម្រាប់ឈ្លោះប្រកែកឡើយ។

កិច្ចប្រជុំក្រុម មានគោលបំណងសម្រាប់ការសន្ទនា មិនមែនការប្រកែកគ្នាទេ។ គោលបំណងនៅក្នុងការសន្ទនា គឺការយល់ពីគ្នាទៅវិញទៅមក។

តាមរយៈការចូលរួមនៅក្នុងកិច្ចប្រជុំក្រុមនេះ ខ្ញុំនឹងតាំងចិត្តថា៖

- ផ្តល់តម្លៃឱ្យគំនិតទាំងអស់។ ប្រាកដថាមានការចូលរួមពីមនុស្សគ្រប់គ្នា សូម្បីតែអ្នកដែលស្ងាត់ស្ងៀមបំផុតដើម្បីចូលរួមក្នុងការសន្ទនា។
- ស្តាប់ដើម្បីយល់ពីអ្នកដទៃ។
- និយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ។ ប្រើប្រាស់ពាក្យ “ខ្ញុំ” មិនមែន “មនុស្ស” ឬ “យើង” ទេ។
- មិននិយាយលើសលុប ឬបង្អាក់អ្នកដទៃ។ មេក្រូមួយ សំឡេងមួយ។

**តោះយើងរៀបចំគម្រោង KENSINGTON ទាំងអស់គ្នា**

KENSINGTONPLAN.ORG

# ប្រវត្តិនៃគោលដៅដែលបានកំនត់ដោយសហគមន៍

អាទិភាពពីគម្រោង North of Lehigh Plan និង Heart of Kensington Plan ផ្តោតលើ៖

- **ពង្រឹងសុវត្ថិភាព និងកាត់បន្ថយទីផ្សារគ្រឿងញៀន។**
- **ការផ្លាស់ប្តូរគន្លងនៃលទ្ធផលសុខភាពអ្នកស្រុក។**
- **ការកែលម្អតំបន់លំនៅដ្ឋានសម្រាប់អ្នកស្រុក និងបង្កើតជម្រើសតំបន់លំនៅដ្ឋានដែលមានតម្លៃសមរម្យនៅលើប្រាក់ជួលដែលកាន់តែយ៉ាប់យ៉ឺន។**
- **កាត់បន្ថយដីទំនេរ និងការកែលម្អ/ការបង្កើន/ការធ្វើឱ្យមានទីវាលបៃតង**
- **ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីបង្កើនលទ្ធភាពទទួលបានទំនិញ និងសេវាកម្មចាំបាច់សម្រាប់អ្នកស្រុក។**
- **ការសម្របសម្រួលដល់ការកែលម្អផ្លូវ។**
- **វិនិយោគលើធនធានមនុស្ស ផ្តល់ឱកាសរីកចម្រើនទាំងចំណេះដឹងផ្ទាល់ខ្លួន និងវិជ្ជាជីវៈ។**

បន្ទាប់ពីការរួបរួមក្នុងការយល់ដឹងអំពីអ្នកស្រុកទាមទារឱ្យមានសកម្មភាពឆ្ពោះទៅរកសុខភាព និងសុវត្ថិភាពសហគមន៍ ការជួបប្រជុំរវាងអ្នកស្រុក ជាមួយក្រុមប្រឹក្សាក្រុងបានកើតឡើងនៅបឋមសិក្សា Elkin School ។ បញ្ជីនៃសកម្មភាពដែលអាចបានដែលបានមកពីកិច្ចប្រជុំ Elkin ត្រូវបានផ្ញើទៅអភិបាល និងអភិបាលក្រុង Philadelphia ។ មានគំនិតមួយចំនួនទាក់ទងនឹងវិធីក្នុងការសម្រេចបាននូវគោលដៅ ប៉ុន្តែសរុបមក ការទាមទារទាំងនោះបានស្មើយ៉ាងច្បាស់លើចំណុចដូចខាងក្រោម៖

- **បញ្ឈប់ Kensington ពីការតាំងទីតាំងសម្រាប់ការប្រើប្រាស់គ្រឿងញៀន។ គាំទ្រដំណើរការបង្រួបបង្រួមសម្រាប់មនុស្សនៅខាងក្រៅសង្កាត់។**
- **សួនកម្សាន្ត និងមជ្ឈមណ្ឌលកម្សាន្ត ត្រូវបានកំណត់ និងអនុវត្តភ្លាមៗជាកន្លែងសុវត្ថិភាពសម្រាប់កុមារ និងក្រុមគ្រួសារ។**
- **បង្កើតយន្តការរាយការណ៍សង្ខេប។**
- **ផ្តល់លំនៅដ្ឋានសម្រាប់ទាំងអស់គ្នា។**
- **ផ្តល់ការព្យាបាលសម្រាប់ទាំងអស់គ្នា។**

# ពាក្យដែលបានប្រើប្រាស់ជាញឹកញាប់

## ឃ្លាមួយចំនួនដែលអ្នកអាចនឹងឮនៅក្នុងការសន្ទនាអំពីអ្នកជិតខាង

**លំនៅដ្ឋានតម្លៃរម្យ**—តំបន់លំនៅដ្ឋានដែលមិនតម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកជួលចំណាយលើសពី 30 ភាគរយនៃប្រាក់ចំណូលសរុបក្នុងគ្រួសាររបស់ពួកគេ ដែលរួមទាំងការចំណាយលើការប្រើប្រាស់នានាក្នុងផ្ទះផងដែរ។

**គម្រោង Anchor** —ជាគម្រោងទាំងឡាយណាដែលនឹងមានឥទ្ធិពលយ៉ាងធំធេងជាវិជ្ជមានលើតំបន់ដែលនៅជុំវិញ។

**វិជ្ជាពលរដ្ឋ**—ក្រុមអ្នកស្រុកដែលបានរៀបចំដែលមានគោលដៅផ្លូវការគឺដើម្បីកែលម្អសង្កាត់តាមរយៈការងារស្ម័គ្រចិត្តដោយសមាជិករបស់ខ្លួន។

**ការអភិវឌ្ឍន៍**—ដំណើរការនៃការបំប្លែងដីទៅជាគោលបំណងថ្មីដោយការសាងសង់ ឬប្រើប្រាស់ធនធានរបស់ទីតាំងនោះ។

**ផ្លូវនៃសុខភាព និងសុខុមាលភាព**—Impact Services និង NKCDC កំពុងសម្របសម្រួលគម្រោងនៅតាមបណ្ដោយ Kensington និង Indiana Avenues ដើម្បីដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពដែលកំណត់ដោយសហគមន៍។

**កាត់បន្ថយទីផ្សារគ្រឿងញៀន**—ធ្វើការដើម្បីកាត់បន្ថយបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន។

**NAC**—អង្គការ Neighborhood Advisory Committee (NAC) ជួយដល់អ្នកស្រុកឱ្យបានស្វែងយល់បន្ថែមអំពីកម្មវិធី City ដែលអាចផ្ដល់អត្ថប្រយោជន៍ដល់ពួកគេ។

**ក្រុម**—ក្រុមនៃមនុស្សដែលបានយល់ព្រមជួបគ្នាដើម្បីរៀបចំផែនការអនាគតរបស់ Kensington!

**កត្តាសង្គមដែលជះឥទ្ធិពលលើសុខភាព**—កត្តាដែលមិនមែនវេជ្ជសាស្ត្រ ដែលប៉ះពាល់ដល់សុខភាពមនុស្សក្នុងកម្រិតធ្ងន់ធ្ងរ ដូចជាផ្នែកតំបន់លំនៅដ្ឋាន អាហារជីវជាតិ ការអប់រំ ការមានការងារធ្វើ ការដឹកជញ្ជូន ការថែទាំកុមារ និងផ្សេងទៀត។

**ការកំណត់នៃតំបន់**—បទប្បញ្ញត្តិរដ្ឋ ឬមូលដ្ឋានដែលគ្រប់គ្រងពីវិធីដែលអចលនទ្រព្យអាចប្រើប្រាស់បាននៅក្នុងទីកន្លែងផ្សេងៗគ្នា។

# សូមពិនិត្យឡើងវិញ ទាំងសំណួរបើក និងកិច្ចការអាទិភាព នាពេលកន្លងមក

គិតអំពីការកំណត់កិច្ចការអាទិភាពឡើងវិញលើគោលដៅ និងអ្វីដែលបន្តពាក់ព័ន្ធបំផុត។

តើសមាសធាតុខាងក្រោមមានភាពបន្ទាន់ប៉ុណ្ណា ហើយតើគោលបំណងជាក់លាក់អ្វីខ្លះដែលសំខាន់បំផុត?

តើប្រធានបទទាំងនេះមានន័យយ៉ាងណាសម្រាប់អ្នក? ហើយតើគោលដៅជាក់លាក់ណាដែលសំខាន់បំផុត?

សូមប្រាប់យើងពីកម្រិតបន្ទាន់នៃកិច្ចការអាទិភាពកន្លងមកសម្រាប់អ្នកដោយប្រើរង្វាស់នៃភាពបន្ទាន់។ 1 បន្ទាន់ខ្លាំង ហើយ 6 មានន័យថា កិច្ចការនោះអាចរង់ចាំបាន។ )

សូមគូសរង្វង់លើលេខតែមួយ ក្នុងចំណោមបី ខាងក្រោម



# សូមពិនិត្យឡើងវិញលើសំណួរ អំពីកិច្ចការអាទិភាពកំណត់ដោយសហគមន៍នាពេលកន្លងមក

**កិច្ចការអាទិភាព កន្លងមក**

កាត់បន្ថយការជួញដូរគ្រឿងញៀន (តើវាមានន័យយ៉ាងណាសម្រាប់អ្នក តើនេះបន្ទាន់ប៉ុណ្ណា?)

______________________________

______________________________

______________________________




សុវត្ថិភាព និងភាពស្អាតនៃទីធ្លាសាធារណៈ ដូចជាផ្លូវថ្នល់ ចិញ្ចើមផ្លូវ ស្ថានីយ៍ដឹកជញ្ជូនសាធារណៈ សួនកម្សាន្ត មជ្ឈមណ្ឌលកម្សាន្ត និងការទាមទារដីទំនេរឡើងវិញ។

______________________________

______________________________

______________________________




ការអភិវឌ្ឍន៍សេដ្ឋកិច្ច (កម្មវិធី គោលនយោបាយ ឬសកម្មភាពដែលស្វែងរកការកែលម្អសុខុមាលភាព និងគុណភាពជីវិតរបស់អាជីវកម្មខ្នាតតូចសម្រាប់សហគមន៍)
(តើវាមានន័យយ៉ាងណាសម្រាប់អ្នក តើនេះជាការបន្ទាន់យ៉ាងណា?)

______________________________

______________________________

______________________________



# សូមពិនិត្យឡើងវិញលើសំណួរ អំពីកិច្ចការអាទិភាពកំណត់ដោយសហគមន៍នាពេលកន្លងមក

កិច្ចការអាទិភាពកន្លងមក (បន្ត)

វិនិយោគលើធនធានមនុស្ស (ផ្តល់ឱកាសរីកចម្រើនប្រកបដោយវិជ្ជាជីវៈ និងផ្ទាល់ខ្លួន)




លំនៅឋាន៖ ការជួលដែលមានតម្លៃសមរម្យ ភាពជាម្ចាស់គេហដ្ឋានដែលមានតម្លៃសមរម្យ បន្ទប់ជួលដែលមានចំណូលទាប ការជួសជុលផ្ទះរបស់អ្នករស់នៅ លំនៅដ្ឋានសម្រាប់ទាំងអស់គ្នា និងលំនៅដ្ឋានបណ្តោះអាសន្ន។ (តើវាមានន័យយ៉ាងណាសម្រាប់អ្នក តើនេះជាការបន្ទាន់យ៉ាងណា?)




សុខភាពអ្នកស្រុក (ការផ្លាស់ប្តូរលទ្ធផលសុខភាពដោយការផ្តល់នូវលទ្ធភាពទទួលបានធនធាន)



# សូមពិនិត្យឡើងវិញលើសំណួរបើកទាំងនេះ អំពី Kensington

## សំណួរបើក

តើសង្កាត់មានចំណុចខ្លាំងអ្វីខ្លះដែលត្រូវពង្រឹង?

តើអ្វីជាបញ្ហាប្រឈមធំបំផុតនៅក្នុងសង្កាត់ ហើយតើពួកគេបានផ្លាស់ប្តូរយ៉ាងដូចម្តេចក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ?

តើអ្នកគិតថាអ្វីដែលរារាំងការផ្លាស់ប្តូរជាវិជ្ជមានយូរអង្វែងនៅ Kensington?

អ្វីដែលធ្វើឱ្យមានភាពតានតឹងដល់អ្នកបំផុតអំពីស្ថានភាពរស់នៅរបស់យើង?

តើយើងអាចកែលម្អជីវភាពរស់នៅរបស់យើងដោយរបៀបណាខ្លះ?

តើយើងត្រូវការអ្វីទៀតដើម្បីផ្លាស់ប្តូរតំបន់រស់នៅរបស់យើង?

តើយើងត្រូវការអ្វីទៀតដើម្បីគាំទ្រសហគមន៍របស់យើង?

# គំនិតថ្មីៗ

តើមានកិច្ចការអាទិភាពដែលអ្នកគិតថាគួរបញ្ចូលទៅក្នុងបញ្ជីទេ? សូមរៀបរាប់នៅខាងក្រោម រួមជាមួយនឹងកម្រិតនៃភាពបន្ទាន់របស់ចំណុចទាំងនោះ

1.




2.




3.





# រៀបចំគម្រោង KENSINGTON ទាំងអស់គ្នា

ចូលរួមចលនាដើម្បី
ការអភិវឌ្ឍដែលដឹកនាំ
ដោយសហគមន៍

អស់រយៈពេលជាច្រើនឆ្នាំ កិច្ចប្រឹងប្រែងដើម្បីដោះស្រាយបញ្ហារបស់ Kensington ត្រូវបានធ្លាក់ចុះកាន់តែតិចតួចទៅ។




ប្រតិបត្តិការSunrise
1998

Philadelphia Inquirer


វិធីសាស្រ្តមួងមួយតំបន់
2012
Philadelphia Inquirer


ការសម្អាតតាមផ្លូវដែក Conrail
2017

ដំណោះស្រាយទាំងនេះ

- ខ្វះនូវធនធាន
- ខ្វះការចូលរួមពីសហគមន៍
- មិនបានដោះស្រាយបញ្ហាដែលទាក់ទងទៅវិញទៅមក

សហគមន៍ Kensington
មានភាពធំ


ការសម្អាតក្នុងតំបន់ដែលអ្នករស់នៅ


កិច្ចប្រជុំសហគមន៍


ផ្លូវសម្រាប់លេង និងការជប់លៀងនៅតាមតំបន់

ឥឡូវនេះ យើងបានឈាន
មកដល់ចំណុចផ្លាស់ប្ដូរពិត
ប្រាកដគឺអាចទៅរួច


រដ្ឋកំពុងតែវិនិយោគលើ
Kensington


រដ្ឋកំពុងតែវិនិយោគលើ
Kensington




ហើយសហគមន៍កំពុងរួមគ្នាដើម្បី
សម្រេចកិច្ចការនានា

# សួនកុមារ McPherson Square 2022



# គម្រោង Impact & NKCDC














នៅឆ្នាំ 2021, ក្រុមប្រឹក្សាក្រុង
មានសវនាការនៅសាលា Lewis
Elkin Middle School

ក្រោយមក ក្រុមចម្រុះនៃសង្កាត់បានសង្ខេបពីកង្វល់ និងដំណោះស្រាយដែលបានពីកិច្ចប្រជុំ និងបានបញ្ជូនសេចក្តីសង្ខេបទាំងនេះសាកិច្ចអំពាវនាវទៅកាន់អភិបាលក្រុង Kenney។



**Noelle Foizen**
នាយក, អង្គភាពឆ្លើយតប Opioid

កិច្ចប្រជុំនេះ
មានគោលដៅចំនួនពីរ

## កិច្ចប្រជុំនេះ
## មានគោលដៅចំនួនពីរ

1. ដើម្បីទទួលបានមតិកែលម្អរបស់អ្នកអំពីអាទិភាព

## កិច្ចប្រជុំនេះមាន
## គោលដៅចំនួនពីរ

1. ដើម្បីទទួលបានមតិកែលម្អរបស់អ្នកអំពីអាទិភាព
2. ដើម្បីស្តាប់អំពីកិច្ចការ និងការផ្តល់យោបល់របស់អ្នកសម្រាប់ Kensington

# កិច្ចព្រមព្រៀងនៃកិច្ចប្រជុំ

## យើងនៅទីនេះដើម្បីស្វែងរកគំនិត។
## យើងនៅទីនេះដើម្បីរៀនសូត្រពីគ្នា។
## យើងនៅទីនេះដើម្បីស្តាប់គ្នា មិនមែនបញ្ចុះបញ្ចូលគ្នាទេ។

កិច្ចប្រជុំក្រុមគឺជាមធ្យោបាយសម្រាប់ការសន្ទនា មិនមែនជាការតស៊ូមតិនោះទេ។ ក្នុងកិច្ចសន្ទនា ការយកយល់គ្នាទៅវិញទៅមកគឺជាគោលដៅ។

តាមរយៈការចូលរួមក្នុងកិច្ចប្រជុំក្រុម ខ្ញុំនឹងព្យាយាមដើម្បី៖

- **ឱ្យតម្លៃសំឡេងទាំងអស់។** ធានាថាមានអ្នកដែលមិនបាននិយាយ អាចមានឱកាសក្នុងការបញ្ចេញយោបល់នៅក្នុងការសន្ទនានេះ។
- **ស្តាប់ដើម្បីបានយល់ពីអ្នកដទៃ។**
- **Speak from my own experience. និយាយពីអ្វីដែលចេញពីបទពិសោធន៍ផ្ទាល់ខ្លួន។** និយាយថា "ខ្ញុំ" មិនមែន "មនុស្សទូទៅ" ឬ "យើង" ទេ។
- **មិននិយាយដាច់ ឬកាត់សម្តីអ្នកដទៃ។** . ឱ្យម្តងមួយ សំឡេងមួយ។